## តើប៊ីបមានអត្ថប្រយោជន៍អ្វីខ្លះ?

ឱកាសសិក្សាដែលមានភាពបត់បែនសម្រាប់យុវជនកម្ពុជា

**ការរៀនតាមអ៊ីនធឺណិត៖** អ្នកអាចសិក្សាបានគ្រប់ពេលវេលា គ្រប់ទីកន្លែង ជាមួយនឹងទិន្នន័យអ៊ីនធឺណិតដែលបានផ្តល់ជូនដោយឥតគិតថ្លៃ។

**សេវាអ៊ីនធឺណិត និងឧបករណ៍សិក្សា៖** នៅមណ្ឌលសិក្សាដែលនៅជិតបំផុត អ្នកសិក្សាអាចមកប្រើប្រាស់ឧបករណ៍វៃឆ្លាត ដូចជាកុំព្យូទ័របន្ទះ និងកុំព្យូទ័រដែលមានអ៊ីនធឺណិតដោយឥតគិតថ្លៃ។

**ការតម្រង់ទិស៖** អ្នកសិក្សានឹងត្រូវបានណែនាំអំពីរបៀបរៀនតាមអ៊ីនធឺណិត។ សេវាប្រឹក្សាយោបល់ទាក់ទងនឹងការងារក៏នឹងត្រូវបានផ្តល់ជូនដោយអ្នកសម្របសម្រួលផងដែរ។

**ការគាំទ្រគ្រប់ពេលវេលា៖** អ្នកសម្របសម្រួលនៅក្នុងមណ្ឌលសិក្សានីមួយៗ នឹងផ្តល់ការគាំទ្រជាបន្តបន្ទាប់ រហូតដល់អ្នកសិក្សាបញ្ចប់កម្មវិធីដោយជោគជ័យ។

**ទទួលបានវិញ្ញាបនបត្រអប់រំមូលដ្ឋាន៖** ក្រោយពេលបញ្ចប់ អ្នកអាចបន្តការបណ្តុះបណ្តាលជំនាញនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ឬ នៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

FREE

**គ្មានការបង់ប្រាក់**
កម្មវិធី ប៊ីប ពុំតម្រូវឲ្យមានការបង់ប្រាក់ឡើយ។



## នរណាខ្លះអាចចុះឈ្មោះបាន?

អ្នកអាចចុះឈ្មោះសិក្សាបានប្រសិនបើអ្នកជា៖



- យុវជនដែលមានអាយុចាប់ពី១៤ឆ្នាំឡើង
- យុវជនដែលបានបោះបង់ការសិក្សា ហើយកំពុងធ្វើការនៅកន្លែងផ្សេងៗ
- យុវជនដែលបានបញ្ចប់ការសិក្សាថ្នាក់ទី៦ ហើយមិនបានបន្ត ឬអ្នកដែលបាន **បោះបង់ការសិក្សា** ត្រឹមថ្នាក់ទី៧ ទី៨ ឬទី៩។
- យុវជនដែលមានពិការភាព

**ដើម្បីទទួលបានព័ត៌មានបន្ថែមសូមទាក់ទងតាមរយៈ ៖**

**010 394 407**

Basic Education Equivalency Programme - BEEP

In collaboration with

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development and Cooperation SDC

# ប៊ីប

កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត

BEEP: BASIC EDUCATION EQUIVALENCY PROGRAMME

ទេសចរណ៍ · សហគ្រិនភាព · រូបវិទ្យា · យេនឌ័រ · ជំនាញមូលដ្ឋានការងារ · បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ · អង់គ្លេស · ភាសាខ្មែរ · គណិតវិទ្យា · គីមីវិទ្យា

**ចុះឈ្មោះ**

**រៀន**

**បញ្ចប់ថ្នាក់ទី ៩!**



**បានគ្រប់ពេល គ្រប់ទីកន្លែង!**




## កម្មវិធីប៊ីបជាអ្វី?

## កម្មវិធីសមមូលអប់រំ កម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (ប៊ីប)

គឺជាគំនិតផ្តួចផ្តើមរួមគ្នារវាង ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការយូណេស្កូ ដើម្បីផ្តល់ការអប់រំតាមអ៊ីនធឺណិតដែលមានភាពបត់បែនដល់យុវជនដែលបានបោះបង់ការសិក្សា ឲ្យបញ្ចប់ការសិក្សាថ្នាក់មូលដ្ឋាន សមមូលថ្នាក់ទី៩។កម្មវិធីប៊ីបជួយដល់យុវជនដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅជាពិសេសអ្នកដែលបានបោះបង់ការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ ឲ្យបញ្ចប់ការអប់រំកម្រិតមូលដ្ឋានដោយសិក្សាតាមអ៊ីនធឺណិត និងមិនមានផលប៉ះពាល់ការងាររបស់ពួកគេ។ អ្នកបញ្ចប់កម្មវិធីប៊ីបដោយជោគជ័យ អាចបន្តចុះឈ្មោះបណ្តុះបណ្តាលជំនាញ នៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឬនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស។ អ្នកសិក្សាអាចសិក្សាដោយឥតគិតថ្លៃ។ អ្នកដែលមិនមានឧបករណ៍វៃឆ្លាត ឬកុំព្យូទ័រ អាចប្រើប្រាស់ឧបករណ៍ទាំងនោះនៅមណ្ឌលសិក្សាប៊ីបបាន។

## ដំណើរការកម្មវិធីប៊ីប



**១. ការចុះឈ្មោះ**

អ្នកអាចចុះឈ្មោះនៅតាមមណ្ឌលសិក្សាប៊ីបដែលនៅជិត ឬអាចចុះឈ្មោះតាមអ៊ីនធឺណិត។



**២. ជម្រើសនៃការសិក្សា**

អ្នកអាចសិក្សា មុខវិជ្ជាគោល និងមុខវិជ្ជាទូទៅ ដើម្បីបន្តការសិក្សា នៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស នៃក្រសួងអប់រំ យុវជន និងកីឡា ឬ សិក្សាមុខវិជ្ជាគោល និងមុខវិជ្ជាបច្ចេកទេស ដើម្បីបន្តការសិក្សានៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ អ្នកក៏អាចសិក្សាមុខវិជ្ជាទាំង១១មុខបានដែរ។



**៣. ការគាំទ្រ**

តាមរយៈការសិក្សាតាមអ៊ីនធឺណិតដោយខ្លួនឯង និងសិក្សានៅតាមមណ្ឌល អ្នកនឹងទទួលបានការគាំទ្រ និងការជួយដោះស្រាយបញ្ហានានា ពីលោកគ្រូអ្នកគ្រូ ដែលជាអ្នកសម្របសម្រួលនៅតាមមណ្ឌលនីមួយៗ។



**៤. ការបញ្ចប់ការសិក្សា**

អ្នកសិក្សាគ្រប់រូបត្រូវចូលប្រឡងបញ្ចប់នៅតាមមណ្ឌលសិក្សាក្រោយពេលបានបញ្ចប់ការសិក្សាគ្រប់មុខវិជ្ជាដែលបានតម្រូវ។ អ្នកប្រឡងជាប់កម្មវិធីប៊ីបដោយជោគជ័យ អាចបន្តចុះឈ្មោះបណ្តុះបណ្តាលជំនាញ នៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឬនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស។

## ជម្រើសនៃការសិក្សា

*អ្នកអាចជ្រើសរើសការសិក្សាដូចខាងក្រោម៖*

សិក្សា មុខវិជ្ជាគោល និងមុខវិជ្ជាទូទៅ នឹងទទួលបានវិញ្ញាបនបត្រសមមូលថ្នាក់ទី៩ ដែលអាចបន្តការសិក្សានៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស នៃ**ក្រសួងអប់រំ យុវជន និងកីឡា**។

សិក្សា មុខវិជ្ជាគោល និងមុខវិជ្ជាបច្ចេកទេស នឹងទទួលបានវិញ្ញាបនបត្រសមមូលថ្នាក់ទី៩ដែលអាចបន្តការសិក្សានៅ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃ**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**។

សិក្សា មុខវិជ្ជាទាំង១១ នឹងទទួលបានវិញ្ញាបនបត្រកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិតសមមូលនឹងថ្នាក់ទី៩ ដែលអាចបន្តការសិក្សានៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ឬ នៅ**គ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**។

## មុខវិជ្ជា

| ល.រ | មុខវិជ្ជា | រយៈពេល | មុខវិជ្ជាគោល | មុខវិជ្ជាទូទៅ | មុខវិជ្ជាបច្ចេកទេស (TVET) |
|---|---|---|---|---|---|
| ១ | ភាសាខ្មែរ | ៨៨ ម៉ោង | ៨៨ ម៉ោង | | |
| ២ | រូបវិទ្យា | ១០៦ ម៉ោង | ១០៦ ម៉ោង | | |
| ៣ | គីមីវិទ្យា | ៤០ ម៉ោង | ៤០ ម៉ោង | | |
| ៤ | គណិតវិទ្យា១ | ៩៤ ម៉ោង | ៩៤ ម៉ោង | | |
| ៥ | គណិតវិទ្យា២ | ៦៨ ម៉ោង | | | ៦៨ ម៉ោង |
| ៦ | យេនឌ័រ | ៥ ម៉ោង | | | ៥ ម៉ោង |
| ៧ | ជំនាញមូលដ្ឋានការងារ | ៥ ម៉ោង | | | ៥ ម៉ោង |
| ៨ | អង់គ្លេស | ៩៦ ម៉ោង | | ៩៦ ម៉ោង | |
| ៩ | សហគ្រិនភាព | ១០ ម៉ោង | | ១០ ម៉ោង | |
| ១០ | ទេសចរណ៍ | ១០ ម៉ោង | | ១០ ម៉ោង | |
| ១១ | បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ | ១០៤ ម៉ោង | | ១០៤ ម៉ោង | |
| | **សរុប** | **៦២៦ ម៉ោង** | **៣២៨ ម៉ោង** | **២២០ ម៉ោង** | **៧៨ ម៉ោង** |

## វិញ្ញាបនបត្រ

កម្មវិធីប៊ីបត្រូវបានទទួលស្គាល់ជាផ្លូវការដោយរាជរដ្ឋាភិបាលកម្ពុជា។ អ្នកដែលប្រឡងជាប់ដោយជោគជ័យ នឹងទទួលបានវិញ្ញាបនបត្រ ដែលមានកម្រិតសមមូលនឹងថ្នាក់ទី៩ ដែលអាចបន្តការសិក្សានៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ឬនៅកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ (C1) នៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។